-សង្កាត់ ជ្រាវ មកជា ឃុំ ជ្រាវ

-សង្កាត់ សៀមរាប មកជា ឃុំ សៀមរាប

-សង្កាត់ នគរធំ មកជា ឃុំ នគរធំ

-សង្កាត់ សំបួរ មកជា ឃុំ សំបួរ

-សង្កាត់ ស្រងែ មកជា ឃុំ ស្រងែ

-សង្កាត់ ចុងឃ្នៀស មកជា ឃុំ ចុងឃ្នៀស

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត សៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ២៥ អនក្រ
## ស្តីពីការប្តូរឈ្មោះឃុំមួយខេត្ត
## សង្កាត់ក្នុងខេត្តបាត់ដំបង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

www.pheakdeylaw.com

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តបាត់ដំបង មកជាស្រុកស្វាយប៉ោ ដែលមានទីតាំងរដ្ឋបាលសាលា ស្រុក នៅភូមិ កំពង់ក្របី ឃុំស្វាយប៉ោ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនដប់ ចំណុះទីរួមខេត្ត មកជាឃុំ ចំនួនដប់ ចំណុះស្រុកស្វាយប៉ោ គឺ ÷

-សង្កាត់ ចំការសំរោង មកជា ឃុំ ចំការសំរោង

-សង្កាត់ ឯកភាព មកជា ឃុំ ស្វាយប៉ោ

-សង្កាត់ មិត្តភាព មកជា ឃុំ ស្លាកែត

-សង្កាត់ ស្វាយប៉ោ១ មកជា ឃុំ ទួលតាឯក

-សង្កាត់ ស្វាយប៉ោ២ មកជា ឃុំ ព្រែកព្រះស្តេច

-សង្កាត់ ស្វាយប៉ោ៣ មកជា ឃុំ រតនៈ

-សង្កាត់ សាមគ្គី មកជា ឃុំ អូរចារ

-សង្កាត់ ក្តុលដូនទាវ មកជា ឃុំ ក្តុលដូនទាវ

-សង្កាត់ អូរម៉ាល់ មកជា ឃុំ អូរម៉ាល់

-សង្កាត់ វត្តគរ មកជា ឃុំ វត្តគរ

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

www.pheakdeylaw.com